**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតជូនពរ

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសដ៏មហាប្រសើរប្រកបដោយក្តីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ខាងមុខនេះ យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរប្រកបដោយកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ដែលបានខិតខំរួមចំណែកយ៉ាងក្លៀវក្លាក្នុងការដឹកនាំ កសាងប្រទេសជាតិ រក្សាបាននូវសុខសន្តិភាព ស្ថិរភាព ព្រមជាមួយនិងការអភិវឌ្ឍលើគ្រប់វិស័យឥតឈប់ឈរ។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះ យើងខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ពិសេស **ទេវតាឆ្នាំថ្មី** ព្រះនាម **គិរិណីទេវី** សូមប្រោសប្រទានជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** និង **លោកជំទាវ** ព្រមទាំង **បុត្រា បុត្រី** មានសុខភាពល្អបរិបូណ៌ និងទទួលបាននូវពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ អង្គារ ៤ កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**